ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្ត កំពង់ធំ**

-សាលក្រមព្រហ្មទណ្ឌលេខៈ.៥៦...(ក)
ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៤
-សំណុំរឿងព្រហ្មទណ្ឌលេខៈ៣៦៧
ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្ត កំពង់ធំ**

បានបើកសវនាការ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤
និង ប្រកាសជាសាធារណៈនៅថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៤
ដោយមានសមាសភាពដូចតទៅៈ-

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានសាលាដំបូងខេត្តកំពង់ធំ

**ចៅក្រមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ធំ
លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ធំ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ធំ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ៦៦៧ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ ដោយមានជនជាប់ចោទៈ

១/ ឈ្មោះ [redacted]វណ្ណា ភេទ ប្រុស អាយុ ២៩ ឆ្នាំ ជាតិ ខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកំពង់ធំ.ទីលំនៅសព្វថ្ងៃភូមិ [redacted] ខេត្តកំពង់ធំ.ឪពុកឈ្មោះ [redacted] សារិន (ស) ម្តាយឈ្មោះ [redacted] ហាត់ (រ) ប្រពន្ធឈ្មោះ [redacted] ភា មានកូន ២០ នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន។ (ដីកាបង្គាប់ឲ្យឃុំខ្លួនលេខៈ៤០៧ ចុះថ្ងៃទៅ ១៨ ខែ កញ្ញា ឆ្នាំ ២០១៣)។

២/ ឈ្មោះ [redacted]ចាន់ថី ហៅ [redacted]ចាន់ផេង ភេទ ប្រុស អាយុ ៣២ ឆ្នាំ ជាតិ ខ្មែរ ទីលំនៅសព្វថ្ងៃភូមិ [redacted] ខេត្តកំពង់ធំ.ឪពុកឈ្មោះ [redacted] ថៃ (រ) ម្តាយឈ្មោះ [redacted]គី (រ) ប្រពន្ធឈ្មោះ [redacted] ផល្លីន មានកូន ០៣ នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន។ (ក្រៅឃុំ)

ដោយមានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធឲ្យជនជាប់ចោទ ។

ដាក់ឲ្យស្ថិតនៅក្រោមកាពិនិត្យពីបទៈ **រក្សាទុក ដឹកជញ្ជូនគ្រឿងញៀន ឬ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅតាមបណ្តោយផ្លូវជាតិលេខ៦ ភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-ដើមបណ្តឹងរដ្ឋប្បវេណី **អយ្យការ** ។

បានឃើញការផ្តល់កាលបរិច្ឆេទសវនាការ ដែលធ្វើឡើងដោយអនុលោមតាមមាត្រា ២៩២ និងមាត្រាបន្តបន្ទាប់ .

**អង្គហេតុ**

-កាលពីថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ វេលាម៉ោង ០២.៣០ នាទីយប់ នៅតាមបណ្តោយផ្លូវជាតិលេខ៦ក្នុងភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ មានករណី **រក្សាទុក ដឹកជញ្ជូនគ្រឿងញៀន ឬ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ជាប្រភេទ(កញ្ឆាក្រៀម)ចំនួន ០៥ បាវ ស្មើ ១៦៦ កញ្ចប់ ទំងន់ ១៦៦ គីឡូក្រាមមួយបានកើតឡើងដែលករណីនេះបង្កដោយជនជាប់ចោទៈ ១/ ឈ្មោះ [redacted]វណ្ណា ភេទ ប្រុស អាយុ ២៩ ឆ្នាំ ២/ ឈ្មោះ [redacted]ចាន់ថី ហៅ [redacted]ចាន់ផេង

គេទ ប្រុស អាយុ ៣២ ឆ្នាំ។ មុនពេលកើតហេតុជនជាប់ចោទឈ្មោះ [redacted] វណ្ណា បានបើកបររថយន្តមួយគ្រឿងម៉ាកកាមរី ស៊ិតពណ៌ស ពាក់ផ្លាកលេខ 2E-8196 កព ដឹកកញ្ចាក្រៀមមានចំនួនដូចខាងលើមកដល់ចំណុចកើតហេតុខាងលើក៏ត្រូវបានសមត្ថកិច្ចកងរាជអាវុធហត្ថស្រុកបារាយណ៍ដឹកនាំដោយលោក [redacted] ប៊ុនហ៊ួរ មេបញ្ជាការកងរាជអាវុធហត្ថស្រុកបារាយណ៍ បានចុះបង្ក្រាបបទល្មើស បានតែម្តង ហើយនចំពោះមុខសមត្ថកិច្ចជនជាប់ចោទបានសារភាពថា សារធាតុញៀន ទាំងនោះជារបស់ជនល្មើសឈ្មោះ [redacted] ចាន់ថី ដែលបានជួលខ្លួនឲ្យដឹកដោយបានបង្កប់នៅក្រោមអី វ៉ាន់អេតចាយ។ បន្ទាប់ពីឃាត់បានមួយយប់សមត្ថកិច្ចក៏បានដោះលែងជនជាប់ចោទឈ្មោះ [redacted] វណ្ណាវិញ រហូតមកដល់ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៣ តំណាងអយ្យការបានចេញដីកាបញ្ជាឲ្យជនជាប់ចោទឈ្មោះ [redacted] វណ្ណា ចូលខ្លួនមកអយ្យការដើម្បីសួរចំលើយហើយក៏បានឃាត់ខ្លួនបញ្ជូនជនជាប់ចោទមកតុលាការឃុំខ្លួនបណ្តោះអាសន្នរហូតដល់សព្វថ្ងៃ។ ដោយឡែកចំពោះជនជនាប់ចោទឈ្មោះ [redacted] ចាន់ថីវិញបានរត់គេចខ្លួនរហូតដល់សព្វថ្ងៃដែរ ហើយចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឲ្យចាប់ខ្លួនរួចហើយតែមិនចាប់បាននៅឡើយទេ។

-ក្រោយពីបានពិភាក្សាដេញដោលរួចរាល់ហើយ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវី

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ និង ពិភាក្សាត្រឹមត្រូវតាមច្បាប់រួចរាល់ហើយ

## សាលាដំបូងខេត្ត កំពង់ធំ

## យល់ឃើញថា

-តាមចំលើយរបស់ជនជាប់ចោទ.សាក្សី.កំណត់ហេតុ និង របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ឃើញថាៈកាលពីថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ វេលាម៉ោង ០២.៣០ នាទីយប់ នៅតាមបណ្តោយផ្លូវជាតិលេខ៦ ភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ពិតជាមានករណី រក្សាទុក ដឹកជញ្ជូនគ្រឿងញៀន ឬ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនជាប្រភេទ(កញ្ចាក្រៀម)ចំនួន ០៥ បាវ ស្មើ ១៦៦ កញ្ចប់ ទំងន់ ១៦៦ គីឡូក្រាមមួយបានកើតឡើងដែលករណីនេះបង្កដោយជនជាប់ចោទៈ ១/ ឈ្មោះ [redacted] វណ្ណា ភេទ ប្រុស អាយុ ២៩ ឆ្នាំ ២/ ឈ្មោះ [redacted] ចាន់ថី ហៅ [redacted] ចានផេង ភេទ ប្រុស អាយុ ៣២ ឆ្នាំ។ មុនពេលកើតហេតុជនជាប់ចោទឈ្មោះ [redacted] វណ្ណា បានបើកបររថយន្តមួយគ្រឿងម៉ាកកាមរី ស៊ិតពណ៌ស ពាក់ផ្លាកលេខ 2E-8196 កព ដឹកកញ្ចាក្រៀមមានចំនួនដូចខាងលើមកដល់ចំណុចកើតហេតុខាងលើក៏ត្រូវបានសមត្ថកិច្ចកងរាជអាវុធហត្ថស្រុកបារាយណ៍ដឹកនាំដោយលោក [redacted] ប៊ុនហ៊ួរ មេបញ្ជាការកងរាជអាវុធហត្ថស្រុកបារាយណ៍ បានចុះបង្ក្រាបបទល្មើស បានតែម្តង ហើយនចំពោះមុខសមត្ថកិច្ចជនជាប់ចោទបានសារភាពថា សារធាតុញៀន ទាំងនោះជារបស់ជនល្មើសឈ្មោះ [redacted] ចាន់ថី ដែលបានជួលខ្លួនឲ្យដឹកដោយបានបង្កប់នៅក្រោមអី វ៉ាន់អេតចាយ។ បន្ទាប់ពីឃាត់បានមួយយប់សមត្ថកិច្ចក៏បានដោះលែងជនជាប់ចោទឈ្មោះ [redacted] វណ្ណាវិញ រហូតមកដល់ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៣ តំណាងអយ្យការបានចេញដីកាបញ្ជាឲ្យជនជាប់ចោទឈ្មោះ [redacted] វណ្ណា ចូលខ្លួនមកអយ្យការដើម្បីសួរចំលើយហើយក៏បានឃាត់ខ្លួនបញ្ជូនជនជាប់ចោទមកតុលាការឃុំខ្លួនបណ្តោះអាសន្នរហូតដល់សព្វថ្ងៃ។ ដោយឡែកចំពោះជនជនាប់ចោទឈ្មោះ [redacted] ចាន់ថី វិញបានរត់គេចខ្លួនរហូតដល់សព្វថ្ងៃដែរ ហើយចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឲ្យចាប់ខ្លួនរួចហើយតែមិនចាប់បាននៅឡើយទេ ដូចអង្គហេតុដែលអយ្យការបានចោទប្រកាន់ប្រាកដមែន។

-ជនជាប់ចោទជានីតិជនមានសមត្ថភាព និង ស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចនូវអំពើរបស់ខ្លួនចំពោះមុខច្បាប់ពោលគឺគ្មានសញ្ញាណណាមួយបង្ហាញថា ជនជាប់ចោទមានសតិវិបល្លាសស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសនោះឡើយ។

-តាមចំលើយរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណា បានឆ្លើយថាៈ កាលពីថ្ងៃខែមិនចាំ ក្រោយចូលឆ្នាំខ្មែរឆ្នាំ ២០១៣ ឈ្មោះ [redacted] ចាន់ថី ហៅពៅ បានមកជួលខ្ញុំឲ្យទៅបើកឡានដឹកទំនិញឲ្យវា ដោយវាឲ្យឈ្នួលមួយជើង ម្ភៃម៉ឺនរៀល ខ្ញុំបាទក៏យល់ព្រម ឈ្មោះ [redacted] ចាន់ថី ហៅពៅ ក៏បានឲ្យខ្ញុំបើករថយន្តម៉ាក់កាមរីគូថស៊ិត ចង្កូតស្តាំ ពណ៌ស ចេញពីទីរួមខេត្តកំពង់ធំ នៅវេលាម៉ោងប្រហែល ៥ ល្ងាច ឆ្ពោះទៅខេត្តព្រះវិហារ ហួសទឹកដីស្រុករវៀង តែខ្ញុំមិនស្គាល់ទីតាំងច្បាស់ទេ ដោយ ឈ្មោះ [redacted] ចាន់ថី ហៅពៅ បើករថយន្តម៉ាកឡង់គ្រីស័រ ពណ៌ស្គរ ចង្កូតឆ្វេង នាំមុខខ្ញុំបាទ ពេលទៅដល់ផ្លូវបំបែកហួសស្រុករវៀងឈ្មោះថី បានឲ្យ

Scanned with CamScanner

ខ្ញុំបាទដេកចាំឡានឡង់គ្រីស័រ ហើយ ឈ្មោះ[redacted] ចាន់ថី ហៅពៅ ក៏បានបើកឡានកាមរីឆ្នៃកាត់គូថក្រោយចេញទៅបាត់ដោយវាប្រាប់ថាវាទៅឡើងទំនិញ រហូតដល់ម៉ោង ៤ ជិតភ្លឺ ទើបឃើញវាបើកឡាននោះមកវិញ ផ្ទុកទំនិញរួចជាស្រេច តែខ្ញុំមិនដឹងថាជាទំនិញអ្វីទេ។ បន្ទាប់មកវាបានឲ្យខ្ញុំបាទទៅបើកឡាននោះទៅភ្នំពេញ ដោយវាបើកឡានពីក្រោយ ពេលមកដល់ផ្សាររវៀង ខ្ញុំក៏ឈប់ហូបបាយ ចាក់សាំងឡាន ឈ្មោះ[redacted] ចាន់ថី ហៅពៅ ក៏បានបើកឡានមកមុនខ្ញុំក៏បើកឡានបន្តទៀត ពេលមកដល់ភ្នំដែក ឈ្មោះ[redacted] ចាន់ថី ក៏បានទូរស័ព្ទមកប្រាប់ខ្ញុំថាៈឲ្យឈប់ឡាននៅភ្នំដែកសិន។ រហូតដល់ម៉ោងជិត ១ រសៀល ខ្ញុំបានបើកឡានចេញពីភ្នំដែក ពេលមកដល់ហួសសាលាវិស័យប្រហែល ១ គីឡូម៉ែត្រ ឈ្មោះ[redacted] ចាន់ថី បានឲ្យខ្ញុំបត់ឆ្វេងតាមផ្លូវទៅស្រុកប្រាសាទសំបូរ វង់មកចេញខាងជើងផ្សារតាំងក្រសាំង ស្រុកសន្ទុក ក៏បានបើកតាមផ្លូវជាតិលេខ ៦ ឆ្ពោះទៅភ្នំពេញ ពេលបើកមកដល់ចំណុចភូមិ ថ្នល់ជាតិ ស្រុកបារាយណ៍ សមត្ថកិច្ចកងរាជអាវុធហត្ថហៅឈប់ឆែកឆេរឃើញកញ្ឆា សមត្ថកិច្ចក៏បានឃាត់ខ្លួនខ្ញុំបាទតែម្តង ចំណែកឈ្មោះ[redacted] ចាន់ថី គេចខ្លួនបាត់។ ស្អែកឡើងសមត្ថកិច្ចកងរាជអាវុធហត្ថបានដឹកខ្ញុំមកដោះលែង នៅក្បែរផ្សារកំពង់ថ្ម ខ្ញុំក៏បានត្រឡប់មកផ្ទះវិញ។ រហូរមកដល់ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១៣ សមត្ថកិច្ចក៏បានហៅខ្ញុំឲ្យទៅបំភ្លឺរឿង ឈ្មោះ[redacted] ចាន់ថី ក៏ឃាត់ខ្លួនខ្ញុំបាទតែម្តង។

ពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំនោះគឺសមត្ថកិច្ចប៉េអឹម២ នាក់ តែពេលគេចាប់ខ្លួនខ្ញុំរួច គេយកខ្ញុំទៅផ្ទះមិនស្គាល់លុះដល់ម៉ោង ១រលងអាធ្រាតប៉េអឹមពីរនាក់នោះបានយកខ្ញុំដាក់ក្នុងឡានរហូតដល់ម៉ោង ៤ ទើបគេយកខ្ញុំមកទម្លាក់នៅក្បែរផ្សារកំពង់ថ្ម ចំពោះប៉េអឹមពីរនាក់នោះខ្ញុំបាទចំណាំមុខសំលាក សក់រួញក្រញ៉ាញ ទាប ក្រោយមកគេប្រាប់ខ្ញុំថាប៉េអឹមម្នាក់នោះ ឈ្មោះ នាងជាប៉េអឹមស្រុកបារាយណ៍។

ខ្ញុំបាទសំណូមពរដល់តុលាការមេត្តាលើកលែងការចោទប្រកាន់ដល់ខ្ញុំបាទផង ព្រោះខ្ញុំបាទមិនដឹងថាទំនិញនោះជាកញ្ឆាទេ។

-តាមចំលើយរបស់សាក្សីឈ្មោះ [redacted] សុខហ៊ាន បានឆ្លើយថាៈកាលពីថ្ងៃខែមិនចាំ ឆ្នាំ ២០១៣ វេលាម៉ោង ៣ នាទៀបភ្លឺ លោកមេបញ្ជាការកងរាជអាវុធហត្ថស្រុកបារាយណ៍ ឈ្មោះ [redacted] ប៊ុនហួរ បានបញ្ជាខ្ញុំបាទ និងឈ្មោះ[redacted] សាវិច ឲ្យទៅយកឡាននៅភូមិថ្នល់ជាតិ ឃុំ បារាយណ៍ ស្រុក បារាយណ៍ ខេត្តកំពង់ធំ ដែលលោកសន សំនៀង ចាប់បាន ពេលនោះខ្ញុំបាទនិងឈ្មោះ[redacted] សាវិច បើកឡានស៊ីវ៉ែន ពេលទៅដល់លោក [redacted] សំនៀង បានប្រាប់ពួកខ្ញុំឲ្យទៅយកឡានមកបន្ទាយ ខ្ញុំបាទក៏បានចុះទៅបើកឡានម៉ាកកាមរី ពណ៌ ស កាត់គូថ ធ្វើទ្រុង តែដេមិនឆេះ ឈ្មោះ[redacted] សាវិច ចង់ខ្សែអូសមកទីបញ្ជាការតែម្តង។ ពេលមកដល់ទីបញ្ជាការលោក [redacted] សំនៀង ក៏បើកឡានរបស់គាត់ទៅផ្ទះ ចំណែកខ្ញុំបាទនិងឈ្មោះ[redacted] សាវិច នៅយាមឡានរហូតទល់ភ្លឺ។

ខ្ញុំបាទទៅដល់កន្លែងរថយន្ត ខ្ញុំបាទមិនបានឃើញលោក [redacted] សំនៀង ឃាត់ខ្លួនមនុស្សទេ។

ខ្ញុំបាទដឹងរឿងរ៉ាវតែប៉ុណ្ណឹងទេ ចំពោះរឿងអ្វីផ្សេងទៀតខ្ញុំបាទមិនបានដឹងទេ។

-តាមចំលើយរបស់សាក្សីឈ្មោះ [redacted] សុផា បានឆ្លើយថាៈក្រោយពេលសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ[redacted] វណ្ណា បានប្រហែលពីរខែ ប្អូនប្រុសនាងខ្ញុំឈ្មោះ[redacted] ចាន់ថី បានមកលេងផ្ទះឈ្មោះ[redacted] វណ្ណា ពេលនោះម្តាយឈ្មោះ[redacted] វណ្ណា បានប្រាប់ថា អាវណ្ណា គេចាប់ទៅបាត់ហើយ វាសួរថាគេចាប់រឿងអ្វី? គាត់ឆ្លើយថាគេចាប់រឿងវាទៅជាមួយម្តែង បន្ទាប់មកវាក៏បានឡើងឡានចេញពីផ្ទះបាត់ ពេលខ្ញុំទូរស័ព្ទមកវា វាប្រាប់ថាវាចេញទៅថៃហើយ មិនបាច់ទូរស័ព្ទមករកវាទៀតទេ ហើយក៏ទូរស័ព្ទមិនចូលរហូតដល់សព្វថ្ងៃ។

ចំពោះរថយន្តដឹកកញ្ឆានេះមិនមែនជារថយន្តរបស់ឈ្មោះ[redacted] ចាន់ថី ទេ គឺជារបស់ឈ្មោះ [redacted] សារ៉ុន ភេទប្រុស នៅភូមិព្រៃគ្គ ឃុំ កំពង់ថ្ម ស្រុក សន្ទុក ខេត្តកំពង់ធំ ទិញពីឈ្មោះ ឆាយ ជាជាងឡាននៅកំពង់ថ្ម ជាប់ខ្លោងទ្វារចូលទៅឃុំក្រយា ក្រោយពេលទិញឡាននេះបានឈ្មោះ [redacted] សារ៉ុន និងឈ្មោះ[redacted] ចាន់ថី បានយករថយន្តនេះមកជួសជុលនៅកំពង់ធំ បន្ទាប់មកឈ្មោះ [redacted] សារ៉ុន បានប្រគល់ឡាននេះឲ្យទៅឈ្មោះ[redacted] ចាន់ថី ដើម្បីយកទៅដឹកឥវ៉ាន់ឲ្យវា បន្ទាប់មកឈ្មោះ [redacted] ចាន់ថី បានទូរស័ព្ទហៅឈ្មោះ[redacted] វណ្ណា នៅបារាយណ៍ ឈ្មោះ [redacted] ចាន់ថី និងឈ្មោះ [redacted] សារ៉ុន មិនបានជិះឡានជាមួយឡានដឹកកញ្ឆានោះទេគឺ ជិះឡានផ្សេង ហើយឈ្មោះ [redacted] សារ៉ុន បានឲ្យឈ្មោះ[redacted] ចាន់ថី ជាអ្នកដោះស្រាយ មិនបាច់ឲ្យចេញឈ្មោះវាទេ។

Scanned with CamScanner

ក្រោយមកសមត្ថកិច្ចប៉ូលីសមកព័ទ្ធផ្ទះ វាក៏បានប្រាប់ថាឈ្មោះ ចាន់ថី ឲ្យជួយចេញលុយវា ព្រោះវាត្រូវការអស់ចំនួន ៣០០០ ដុល្លាអាមេរិក តែឈ្មោះ [redacted] ចាន់ថី ថាវាគ្មានលទ្ធភាពទេ។

ចំពោះរឿងដែលនាងខ្ញុំរៀបរាប់ខាងលើនេះគឺនាងខ្ញុំដឹងតាមរយៈឈ្មោះ [redacted] ចាន់ថី រៀបរាប់ប្រាប់នាងខ្ញុំ។

នាងខ្ញុំដឹងរឿងរ៉ាវតែប៉ុណ្ណឹងទេ ចំពោះរឿងអ្វីផ្សេងទៀតនាងខ្ញុំមិនបានដឹងទេ។

-តាមអំណានចំលើយរបស់សាក្សីឈ្មោះ [redacted] ឆាយ បានឆ្លើយថាៈកាលពីថ្ងៃខែមិនចាំ មុនចូលឆ្នាំខ្មែរឆ្នាំ ២០១៣ ខ្ញុំបាទបាន ទិញរថយន្តម៉ាក កាមរី ពណ៌ស គូថស្វិត កាត់គូថធ្វើទ្រុង មិនចាំស្លាក់លេខ ពីឈ្មោះធីម គេទ ប្រុស ជាអ្នករស់នៅក្រយា តែមិន ស្គាល់ភូមិទេក្នុងតម្លៃ ៦៥០ ដុល្លាអាមេរិក តែមិនបានធ្វើកិច្ចសន្យាទិញលក់ទេ  លុះក្រោយចូលឆ្នាំខ្មែររួច ខ្ញុំបានលក់រថយន្តនេះទៅមនុស្សម្នាក់មិនស្គាល់ឈ្មោះ គ្រាន់តែស្គាល់ផ្ទះគាត់នៅខាងត្បូងផ្លូវជាតិលេខ៦ ទល់មុខផ្ទះអភិបាលស្រុកសន្ទុក ខេត្ត កំពង់ធំ ក្នុងតម្លៃ ៧០០ ដុល្លាអាមេរិក តែមិនបានធ្វើកិច្ចសន្យាទិញលក់ទេ។

ខ្ញុំបាទមិនបានដឹងថាអ្នកទិញឡានរបស់ខ្ញុំយកទៅដឹកគ្រឿងញៀនទេ ព្រោះក្រោយពីទិញឡានខ្ញុំបាទហើយ ខ្ញុំមិនដែលឃើញមុខវារហូតដល់សព្វថ្ងៃ។

ខ្ញុំបាទដឹងរឿងរ៉ាវតែប៉ុណ្ណឹងទេ ចំពោះរឿងអ្វីផ្សេងទៀតខ្ញុំបាទមិនបានដឹងទេ។

-តាមអំណានចំលើយរបស់សាក្សីឈ្មោះ [redacted] ប៊ុនហួរ បានឆ្លើយថាៈកាលពីថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៣ វេលាម៉ោង ៤ នាទី ទៀបភ្លឺ ឈ្មោះ [redacted] សំនៀង ជាមេបញ្ជាការរងកងរាជអាវុធហត្ថស្រុក បារាយណ៍ បានទូរស័ព្ទមកប្រាប់ខ្ញុំថាឲ្យទៅយកឡាននៅភូមិ ថ្នល់ជាតិ ឃុំបារាយណ៍ ស្រុក បារាយណ៍ ខេត្តកំពង់ធំ ដោយវាប្រាប់ថាជាឡានដឹកគ្រឿងញៀន ពេលនោះខ្ញុំក៏បានបញ្ជាកំលាំង ឲ្យទៅជួយឡានមករក្សាទុកនៅទីបញ្ជាការកងរាជអាវុធហត្ថស្រុកបារាយណ៍ ពេលកំលាំងយកឡានមកដល់ទើបដឹងថាជាប្រភេទឡានកាមរីគូថស្វិតកាត់គូថក្រោយធ្វើជាទ្រុង ដោយមានដឹកឥវ៉ាន់អេតចាយពីលើបង្កប់កញ្ឆា ៥ បាវនៅខាងក្រោមចំនួន ១៦៦ កញ្ចប់តូច ទម្ងន់ ១៧២ គីឡូក្រាម។ ពេលខ្ញុំឲ្យកំលាំងទៅយកនោះគឺអ្នកបើកឡានរត់បាត់ហើយ។

ខ្ញុំសូមបញ្ជាក់បន្ថែមថាៈពេលឈ្មោះ [redacted] សំនៀង រាយការណ៍ប្រាប់ខ្ញុំឲ្យទៅយកឡាននោះ វាបានប្រាប់ថាវាកំពុងប្រដេញមុខសញ្ញា និងសុំកំលាំងអន្តរាគមន៍ដើម្បីយករថយន្តជនមុខសញ្ញាចតទុកចោល ពេលខ្ញុំក៏បានបញ្ជាកំលាំងរបស់ខ្ញុំបាទពីរនាក់ មានឈ្មោះ [redacted] សាវិច និងឈ្មោះ [redacted] សុខហាន ដើម្បីឲ្យទៅយកឡានមករក្សាទុកនៅទីបញ្ជាការ។ នៅពេលឈ្មោះ [redacted] សំនៀង ដេញចាប់មុខសញ្ញាវាបានរាយការណ៍មកប្រាប់ខ្ញុំវិញថាៈជនល្មើសរត់បាត់អស់ហើយ ខ្ញុំបាទក៏បានរាយការណ៍មកលោកមេបញ្ជាការកងរាជអាវុធហត្ថខេត្តកំពង់ធំ បន្ទាប់មកកងរាជអាវុធហត្ថខេត្ត កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងព្រះរាជអាជ្ញារង បានចុះទៅដល់កន្លែងកើតហេតុ ពិនិត្យនិងកសាងសំណុំរឿងមកតុលាការ។

ក្រោយពេលកើតហេតុសមត្ថកិច្ចបានស្រាវជ្រាវរកឃើញម្ចាស់ឡានតាមលិខិតទិញលក់ឡានជាបន្តបន្ទាប់រហូតដល់ចាប់ខ្លួនឈ្មោះ [redacted] វណ្ណា ។

ខ្ញុំបាទដឹងរឿងរ៉ាវតែប៉ុណ្ណឹងទេ ចំពោះរឿងរ៉ាវដែលគេចោទប្រកាន់ថាឈ្មោះ [redacted] សំនៀង ចាប់បង្ខាំងឈ្មោះ [redacted] វណ្ណា ជំរិតទារប្រាក់នោះខ្ញុំបាទមិនបានដឹងទេ។

ចំពោះឈ្មោះ [redacted] សំនៀង នេះត្រូវបានមេបញ្ជាការកងរាជអាវុធហត្ថខេត្ត បានទៅប្រកាសដកឈ្មោះ [redacted] សំនៀង ឲ្យទៅបំរើការងារនៅទៅបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស តាំងពីខែ កញ្ញា ឆ្នាំ ២០១៣ ម្លេះ។

-តាមអំណានចំលើយរបស់សាក្សីឈ្មោះ [redacted] សាវិច បានឆ្លើយថាៈកាលពីថ្ងៃខែមិនចាំ ឆ្នាំ ២០១៣ វេលាម៉ោង ៣ នាទី ទៀបភ្លឺ លោក [redacted] ប៊ុនហួរ ជាមេបញ្ជាការកងរាជអាវុធហត្ថស្រុកបារាយណ៍ បានបញ្ជាខ្ញុំបាទ និងឈ្មោះ [redacted] សុខហ៊ាន ឲ្យទៅយក ឡាននៅភូមិថ្នល់ជាតិ ឃុំ បារាយណ៍ ស្រុក បារាយណ៍ ខេត្តកំពង់ធំ ពេលនោះខ្ញុំបាទបើកឡានស៊ីរ៉ែនទៅជាមួយឈ្មោះ [redacted] សុខហ៊ាន ពេលទៅដល់ឃើញឈ្មោះ [redacted] សំនៀង ជាមេបញ្ជាការរងកងរាជអាវុធហត្ថស្រុកបារាយណ៍ ឈរនៅក្បែរនោះនិងឃើញឡានម៉ាកកាមរីគូថស្វិតកាត់គូថ ពណ៌ស មានផ្ទុកឥវ៉ាន់នៅពីលើ ០៥ បេ ខ្ញុំបាទក៏ឲ្យឈ្មោះ [redacted] សុខហ៊ាន ចុះបើកឡាននោះទៅបញ្ជាការវិញទាំងបីនាក់ ដោយខ្ញុំបាទបើកឡានស៊ីរ៉ែន ឈ្មោះ [redacted] សុខហ៊ាន បើកឡាននោះ និងឈ្មោះ

Scanned with CamScanner

[redacted] សំនៀង បើកឡានរបស់គាត់ ពេលទៅដល់បញ្ជាការរបស់លោក [redacted] ប៊ុនហួរ បានបញ្ជាខ្ញុំឲ្យទៅយាមឡានឲ្យបានត្រឹមត្រូវ ចំណែក ឈ្មោះ [redacted] សំនៀង បានបើកឡានទៅផ្ទះរបស់គាត់។

ពេលទៅដល់កន្លែងរថយន្តពុំឃើញមានការឃាត់ខ្លួនមនុស្សទេ។

ខ្ញុំបាទដឹងរឿងរ៉ាវតែប៉ុណ្ណឹងទេ ចំពោះរឿងអ្វីផ្សេងទៀតខ្ញុំបាទមិនបានដឹងទេ។

-តាមអំណានចំលើយរបស់សាក្សីឈ្មោះ [redacted] ថៃ បានឆ្លើយថាៈខ្ញុំបាទបានទិញឡានម៉ាកកាមរីចង្កូតស្តាំ ពណ៌ស អត់ចាំស្លាក់ លេខ ពីឈ្មោះ លាង រស់នៅភូមិពានា ឃុំ ក្បៀងរាយ ស្រុក កញ្ជៀច ខេត្ត ព្រៃវែង ក្នុងតម្លៃ ១២៥០ ដុល្លាអាមេរិក ពេលទិញឡានបាន ខ្ញុំបាទយកមកបន្ថែមទ្រុង ដើម្បីដាក់ឥវ៉ាន់គឺដឹកទឹកកកនៅភូមិពព្រេង ឃុំ ស្តី ស្រុក ចំណារលើ ខេត្តកំពង់ចាម លុះ ប្រហែលជាបាន ៤ ខែ ក្រោយមកខ្ញុំបាទបានអំពាវនាវលក់ឡាននេះ ទើបឈ្មោះ ធី អាយុ ប្រហែល ៥០ ឆ្នាំ រស់នៅភូមិផ្សារក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ បាននាំមនុស្សប្រុសម្នាក់អាយុប្រហែល៣០ឆ្នាំ មកទិញឡានខ្ញុំបាទដោយលក់បានក្នុងតម្លៃ៧៥០ ដុល្លាអាមេរិក នៅពេលទិញឡាននេះខ្ញុំមិនបានធ្វើលិខិតស្នាមទិញលក់អ្វីទេ ដោយសំអាងឯកសាររថយន្តមានស្រាប់ ហើយខ្ញុំមិន បានដឹងថាអ្នកទិញរថយន្តនោះ គេយកទៅប្រកបអ្វីឡើយ គិតមកពេលនេះមានរយៈពេលប្រហែល ១ ឆ្នាំ ហើយ។ ខ្ញុំបាទមិន មានពាក់ព័ន្ធអ្វីជាមួយរថយន្តនេះទៀតឡើយ។

ចម្លើយរបស់ខ្ញុំបាទសូមអស់ត្រឹមនេះ។

-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខៈ ៣១៣១/១៤ ម.ព.អ.ជ.ប.គ.៣ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់ឲ្យឃើញថាសារធាតុដែលសង្ស័យថាជាគ្រឿងញៀនដែលដឹកជញ្ជូនដោយជនជាប់ចោទខាងលើនេះគឺពិតជាមានវត្តមានសារធាតុញៀន "កញ្ឆាស្ងួត " ឈ្មោះ តេត្រាអ៊ីដ្រូកានណាប៊ីណុល "THC" ហើយបើយោងតាមខ្លឹមសារនៃមាត្រា៤០ កថាខណ្ឌ ៧ ចំណុច៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ជនជាប់ចោទត្រូវទទួលរងទណ្ឌកម្មពន្ធនាគារពី ២០(ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប)ឆ្នាំ ឬអស់មួយជីវិត និងផ្តន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០(សែសិបលាន)រៀល ទៅ ១០០.០០០.០០០ (មួយរយលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ៖

៥.កញ្ឆាស្ងួត មានបរិមាណចាប់ពី ៦០ គីឡូក្រាមឡើងទៅ។

-តាមមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌបានបញ្ញត្តិដូច្នេះថា "នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យផង តុលាការអាចប្រកាសៈ

១.ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ

២.ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ

៣.ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ។

-តាមការពិនិត្យរាល់ឯកសារនានាដែលមាននៅក្នុងសំណុំរឿង និង ចំលើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណា ថាមិនបានដឹងថាខ្លួនដឹកកញ្ឆានោះ គឺមិនអាចឲ្យតុលាការជឿជាក់បានទេ ដោយហេតុថាការដោះសារនេះជនជាប់ចោទមិនមានភស្តុតាងណាមួយយកមកដោះបន្ទុកដល់ខ្លួនឡើយ តែផ្ទុយមកវិញតាមរយៈចំលើយនេះបានបញ្ជាក់ថាទាំងជនជាប់ចោទឈ្មោះ [redacted] វណ្ណា និងទាំងជនជាប់ចោទឈ្មោះ [redacted] ចាន់ថី គឺពិតជាបាន ប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន។

-អំពើរបស់ជនជាប់ចោទទាំងពីរនាក់ខាងលើគឺបានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម ពិសេសប៉ះពាល់សុខភាពសាធារណៈ គប្បីតុលាការផ្តន្ទាទោសឲ្យបានតឹងរ៉ឹងបំផុត ។

-តំណាងអយ្យការបានចេញដីកាកោះហៅជនជាប់ចោទទាំងពីរនាក់ឲ្យចូលមកបំភ្លឺតុលាការ ត្រឹមត្រូវតាមនីតិវិធីច្បាប់រួចរាល់ហើយ តែពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ចាន់ថី មិនបានចូលមកបំភ្លឺតុលាការទេ គប្បីតុលាការសម្រេចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទរូបនេះយកមកអនុវត្តទោសតាមច្បាប់តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-វត្ថុតាងរួមមានៈសារធាតុញៀនប្រភេទកញ្ឆាក្រៀម ចំនួន ០៧ បេ ស្មើនិង ១៦៦ កញ្ចប់ ទំងន់ ១៦៦ គីឡូក្រាម គប្បីតុលាការរឹបអូសនិងបំផ្លាញចោល រីឯរថយន្តម៉ាកកាមរី ពណ៌ស ពាក់ស្លាកលេខៈ ភ្នំពេញ 2E 8196 គប្បីតុលាការសម្រេចរឹបអូសទុកសម្បត្តិរដ្ឋ។

-មានពិរុទ្ធភាពលើជនជាប់ចោទៈ

១/ ឈ្មោះ [redacted] វណ្ណា ភេទ ប្រុស អាយុ ២៩ ឆ្នាំ ជាតិ ខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកំពង់ធំ.ទីលំនៅសព្វថ្ងៃភូមិ [redacted] ខេត្តកំពង់ធំ.ឪពុកឈ្មោះ [redacted] សាវៃ(ស) ម្តាយឈ្មោះ [redacted] ហាត់ (រ) ប្រពន្ធឈ្មោះ [redacted] ភា មានកូន ២០ នាក់ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន។

២/ ឈ្មោះ [redacted] ចាន់ថី ហៅ [redacted] ចានផេង ភេទ ប្រុស អាយុ ៣២ ឆ្នាំ ជាតិ ខ្មែរ ទីលំនៅសព្វថ្ងៃភូមិ [redacted] ខេត្តកំពង់ធំ.ឪពុកឈ្មោះ [redacted] ថៃ (រ) ម្តាយឈ្មោះ [redacted] គី (រ) ប្រពន្ធឈ្មោះ ទា ផល្លីន មានកូន ០៣ នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន។

ពីបទៈ រក្សាទុក ដឹកជញ្ជូនគ្រឿងញៀន ឬ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅតាមបណ្តោយផ្លូវជាតិលេខ ៦ ភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៧ ចំណុច៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានក្នុងដំណាក់កាលសវនាការថា តំណាងអយ្យការប្តឹងសុំរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខៈ៤៥៥/២០១៤ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៤ ទុកជាបានការដដែល និង ប្តឹងសុំឲ្យចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

-មេធាវីការពារសិទ្ធឲ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានការពារក្នុងដំណាក់កាលសវនាការថា សុំតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួនផង។

-ជនជាប់ចោទសំណូមពរសុំតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១/- ផ្តន្ទាទោសលើ

ក.ឈ្មោះ [redacted] វណ្ណា

ខ.ឈ្មោះ [redacted] ចាន់ថី

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ២០ "ម្ភៃ"ឆ្នាំ ពីបទៈ រក្សាទុក ដឹកជញ្ជូនគ្រឿងញៀន ឬ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅតាមបណ្តោយផ្លូវជាតិលេខ ៦ ភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ បទល្មើសដែលមានចែក និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៧ ចំណុច ៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២/-បង្គាប់ឲ្យចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ចាន់ថី យកមកអនុវត្តទោសក្នុងពន្ធនាគារចាប់ពីពេលនេះតទៅ។

៣/-វត្ថុតាងមានសារធាតុញៀនប្រភេទកញ្ឆាក្រៀម ចំនួន ០៧ បេ ស្មើនិង ១៦៦ កញ្ចាប់ ទំងន់ ១៦៦ គីឡូក្រាម ត្រូវរឹបអូសនិងបំផ្លាញចោល រីឯរថយន្តម៉ាកកាមរី ពណ៌ស ពាក់ស្លាកលេខៈ ភ្នំពេញ 2E 8196 ត្រូវរឹបអូសទុកសម្បត្តិរដ្ឋ។

៤/-សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វណ្ណា និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ចាន់ថី។

ទុកសិទ្ធឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]